ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា
លេខ: ០៤៤១ វ.ប.ក

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការជ្រើសរើសនិស្សិតចូលរៀនកម្រិតបណ្ឌិត នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សម្រាប់ឆ្នាំសិក្សា ២០២២-២០២៣

### I- ចំនួនជ្រើសរើស

ក្នុងឆ្នាំសិក្សា ២០២២-២០២៣នេះ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (វ.ប.ក) នឹងជ្រើសរើសនិស្សិតឱ្យចូលរៀន នៅកម្រិតបណ្ឌិត សិក្សាពេញម៉ោង ចំនួន ២៥ នាក់ លើមុខជំនាញខាងក្រោម ៖

១. ទឹក និងបរិស្ថាន ........................................................................ចំនួន ០៥ នាក់
២. បច្ចេកវិទ្យាអាហារ និងអាហារូបត្ថម្ភ...............................................ចំនួន ០៥ នាក់
៣. មេកាត្រូនិច និងបច្ចេកវិទ្យាព័ត៌មាន...............................................ចំនួន ០៥ នាក់
៤. វិទ្យាសាស្ត្ររូបធាតុ និងគ្រឿងបង្គុំ .....................................................ចំនួន ០៥ នាក់
៥. បច្ចេកវិទ្យា និងការគ្រប់គ្រងថាមពល ...............................................ចំនួន ០៥ នាក់

### II- អាហារូបករណ៍

១. អាហារូបករណ៍ វ.ប.ក ចំនួន ០៥ កន្លែងសម្រាប់បុគ្គលិកនៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា៖
- លើថ្លៃចុះឈ្មោះនិងថ្លៃសិក្សា ១០០% រយៈពេលបីឆ្នាំសិក្សា (១៩០០ ដុល្លារ x ៣ ឆ្នាំ)
- ប្រាក់ឧបត្ថម្ភប្រចាំខែចំនួន ៣៥០ដុល្លារ ក្នុងមួយខែ។

### III- រចនាសម្ព័ន្ធសិក្សា

កម្មវិធីសិក្សានេះ ជាកម្មវិធីសិក្សាកម្រិតបណ្ឌិតស្រាវជ្រាវ មានរយៈពេល ៣ ឆ្នាំ (អតិបរមា ៦ ឆ្នាំ) សមមូលនឹង ៥៤ ក្រេឌីត (ការសិក្សាមុខវិជ្ជាចំនួន ២១ ក្រេឌីត និងការស្រាវជ្រាវនិងនិក្ខេបបទ ចំនួន ៣៣ ក្រេឌីត)។ ព័ត៌មានលំអិតស្ដីពីកម្មវិធីសិក្សាសូមទាញយកពី https://t.me/itc_graduate_school/43។

### IV- លក្ខខណ្ឌជ្រើសរើស

បេក្ខជនដែលនឹងត្រូវជ្រើសរើសឱ្យចូលរៀន ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

១. មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬមានសញ្ញាបត្រសមមូល
២. មានសញ្ញាបត្រវិស្វករ សញ្ញាបត្របរិញ្ញាបត្រវិទ្យាសាស្ត្រ ឬមានសញ្ញាបត្រសមមូល
៣. មានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់វិទ្យាសាស្ត្រឬវិស្វកម្ម ឬមានសញ្ញាបត្រសមមូល
៤. ការសិក្សាកម្រិតឧត្តមសិក្សាកន្លងមកមានជាប់ពាក់ព័ន្ធនឹងមុខជំនាញ និងប្រធានបទស្រាវជ្រាវ
៥. ទទួលបាននិទ្ទេសល្អ (មធ្យមភាគសរុប GPA ចាប់ពី ៣.០០) ឬជានិស្សិតសរសេរនិក្ខេបបទដើម្បីបញ្ចប់ការសិក្សាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់
៦. មានគម្រោងស្រាវជ្រាវបឋមមួយច្បាស់លាស់
៧. មានចំណេះដឹងភាសាអង់គ្លេស ឬភាសាបារាំងក្នុងកម្រិតអាចប្រើប្រាស់បាន
៨. មានមូលដ្ឋានគ្រឹះព័ត៌មានវិទ្យាសមស្របដើម្បីបម្រើដល់ការស្រាវជ្រាវ
៩. មានប្រភពហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់ទ្រទ្រង់ការសិក្សាស្រាវជ្រាវឱ្យបានចប់ស្ពាពរតាមកាលកំណត់

### V- សំណុំលិខិតនៃការដាក់ពាក្យសុំ

បេក្ខជនដាក់ពាក្យសុំត្រូវភ្ជាប់ឯកសារដូចខាងក្រោម៖



មហាវិថី សហពន្ធ័រុស្ស៊ី ប្រអប់សំបុត្រលេខ ៨៦ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា – www.itc.edu.kh
ទូរស័ព្ទ : (855) 23 880 370 ទូរសារ : (855) 23 880 369 E-mail : info@itc.edu.kh

១. សំណើពាក្យសុំជ្រើសរើសជាភាសាអង់គ្លេស (មានគំរូ)...............................................................១ច្បាប់
២. ប្រវត្តិរូបសង្ខេប (CV) មានបិទរូបថត ...............................................................................១ច្បាប់
៣. លិខិតបិទជិតរបស់អ្នកផ្តល់យោបល់ ៣ រូប ក្នុងនោះមានអ្នកគ្រប់គ្រង ១ រូប
និងសាស្ត្រាចារ្យធ្លាប់ណែនាំ ឬបង្រៀន ២ រូប ..........................................................................១ច្បាប់
៤. ច្បាប់ចម្លងសញ្ញាបត្រពាក់ព័ន្ធដែលមានការបញ្ជាក់ត្រឹមត្រូវពីអាជ្ញាធរមានសមត្ថកិច្ច .............១ច្បាប់
៥. ព្រឹត្តិបត្រពិន្ទុដែលបានសិក្សានៅកម្រិតបរិញ្ញាបត្រនិងបរិញ្ញាបត្រជាន់ខ្ពស់ ...........................១ច្បាប់
៦. លិខិត ឬវិញ្ញាបនបត្របញ្ជាក់ពីកម្រិតចំណេះដឹងផ្នែកភាសាអង់គ្លេស ឬភាសាបារាំង .............១ច្បាប់
៧. លិខិត ឬវិញ្ញាបនបត្របញ្ជាក់ពីកម្រិតមូលដ្ឋានគ្រឹះព័ត៌មានវិទ្យា (បើមាន)...............................១ច្បាប់
៨. សំណើគម្រោងស្រាវជ្រាវបឋម (ជាភាសាអង់គ្លេស ឬបារាំង) ......................................................១ច្បាប់
៩. លិខិតបញ្ជាក់ស្ថានភាពហិរញ្ញវត្ថុ (Financial Statement) (សូមភ្ជាប់មកជាមួយនូវកិច្ចសន្យា
ការងារឬកិច្ចសន្យាបណ្ឌិត លិខិតអាហារូបករណ៍ ឬអំណះអំណាងហិរញ្ញវត្ថុពីធនាគារ។ល។) ១ច្បាប់
១០. និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ...................................................................................១ច្បាប់
១១. អត្ថបទ ឬរបាយការណ៍ស្រាវជ្រាវផ្សេងៗ (បើមាន) ...............................................................១ច្បាប់
១២. លិខិតអនុញ្ញាតពីទីកន្លែងធ្វើការក្នុងករណីបេក្ខជនកំពុងបំពេញការងារ.....................................១ច្បាប់
១៣. រូបថតថ្មីទំហំ ៤x៦...................................................................................................................២សន្លឹក

## VI- កាលបរិច្ឆេទទទួលពាក្យ និងកន្លែងទទួលពាក្យ

បេក្ខជនអាចយកគំរូពាក្យសុំនៅសាលាក្រោយបរិញ្ញាបត្រនៃ វ.ប.ក ៖ បន្ទប់លេខ១១០ អគារ B មហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ឬអាចទាញយកគំរូពាក្យសុំនេះជាទម្រង់ PDF តាមរយៈទំព័រហ្វេសប៊ុកផ្លូវការរបស់សាលាក្រោយបរិញ្ញាបត្រនៃ វ.ប.ក www.facebook.com/itcgraduate ឬ Telegram Channel https://t.me/s/itc_graduate_school។ បេក្ខជនអាចមកយក និងដាក់ ពាក្យសុំចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង ១១:០០ ព្រឹកនៅសាលាក្រោយបរិញ្ញាបត្រនៃ វ.ប.ក។ បេក្ខជនត្រូវផ្ញើសំណុំឯកសារពាក្យសុំជាពីរទម្រង់គឺ Hard Copy និង PDF (សូមផ្ញើមកកាន់ Email: graduate@itc.edu.kh) ឱ្យបានមុនពេលផុតកំណត់។

## VII- ការជ្រើសរើស

ការជ្រើសរើសនិស្សិតឱ្យចូលរៀន នឹងត្រូវធ្វើឡើងជា២ដំណាក់កាល ៖ ដំណាក់កាលទី១ ជាការវាយតម្លៃលើសំណុំលិខិតពាក្យសុំរបស់បេក្ខជន (Shortlist) និងដំណាក់កាលទី២ ជាការវាយតម្លៃលើគម្រោងស្រាវជ្រាវបឋមរបស់បេក្ខជនតាមរយៈសម្ភាសន៍ផ្ទាល់មាត់និងការធ្វើបទបង្ហាញរបស់បេក្ខជន។
<u>បញ្ជាក់</u>៖ មានតែបេក្ខជនដែលជាប់ក្នុងដំណាក់កាលទី១ប៉ុណ្ណោះ ដែលអាចឈានមកដំណាក់កាលទី២នេះ។

## VIII- ការប្រកាសលទ្ធផល

ការប្រកាសលទ្ធផលស្ថាពរនឹងប្រព្រឹត្តទៅនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ ។

## IX- ការចុះឈ្មោះចូលរៀន

ការចុះឈ្មោះចូលរៀននឹងប្រព្រឹត្តទៅនៅថ្ងៃបន្ទាប់ពីថ្ងៃប្រកាសលទ្ធផល។

## X- បវេសនកាល

កាលបរិច្ឆេទនៃបវេសនកាលនឹងជូនដំណឹងនៅពេលក្រោយ។

## XI- តម្លៃសិក្សា

និស្សិតបណ្ឌិតវិស្វកម្មគ្រប់មុខជំនាញត្រូវបង់ថ្លៃសិក្សា ១៩០០ (មួយពាន់ប្រាំបួនរយ) ដុល្លារសហរដ្ឋអាមេរិច សម្រាប់ការបង់មួយឆ្នាំសិក្សានិង ៩៥០ (ប្រាំបួនរយហាសិប) ដុល្លារសហរដ្ឋអាមេរិចសម្រាប់ការបង់មួយឆមាស។

**<u>បញ្ជាក់</u>៖** សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកសាលាក្រោយបរិញ្ញាបត្រនៃ វ.ប.ក បន្ទប់លេខ ១១០ អគារ B ឬ តាមរយៈ Email: graduate@itc.edu.kh ។

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២

**នាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា**

**បណ្ឌិត ប៉ូ គីមថុ**

**<u>ចម្លងជូន</u> ៖**

- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា
- អគ្គនាយកដ្ឋានឧត្តមសិក្សា
- នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ « <u>ដើម្បីជ្រាបជាព័ត៌មាន</u> »
- ការិយាល័យសិក្សា
- គ្រប់ដេប៉ាតឺម៉ង់របស់ វ.ប.ក
- ផ្នែកផ្សព្វផ្សាយព័ត៌មាន « <u>ដើម្បីផ្សព្វផ្សាយ</u> »
- កាលប្បវត្តិ
- ឯកសារ វបក